ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង រវាង
# នៃក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក
# និង
# ប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក
# នៃក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក
# ស្តីពី
# ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ដោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារបញ្ហាកង្វះវត្ថុធាតុដើម និងមិនមានអ្នកបញ្ជាទិញ

ឆ្នាំពីរពាន់ម្ភៃពីរ ខែធ្នូ ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅក្នុងការិយាល័យរដ្ឋបាលក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក ដែលមានអាសយដ្ឋានស្ថិតនៅផ្លូវ២១A ភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល បានរៀបចំការប្រជុំមួយរវាងក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក និងប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព ប្រធានក្រុមគ្រប់ផ្នែកប្រចាំក្រុមហ៊ុន។

ក្នុងអង្គប្រជុំ កញ្ញា សន ចាន់វត្តី ដែលជាប្រធានរដ្ឋបាល បានមានមតិស្វាគមន៍ និងសំណេះសំណាលជាមួយបងប្អូនប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីពទាំងពីរក្រុម និងប្រធានក្រុមគ្រប់ផ្នែក ក្នុងអង្គប្រជុំនោះផងដែរ កញ្ញា សន ចាន់វត្តី បានជម្រាបជូនដំណឹងដល់បងប្អូន ប្រតិភូបុគ្គលិក (តំណាងកម្មករ) និងតំណាងសហជីព ប្រធានក្រុមគ្រប់ផ្នែកទាំងអស់ អំពីស្ថានភាពបច្ចុប្បន្នដែលប្រឈមមុខយ៉ាងខ្លាំងនូវ បញ្ហាកង្វះវត្ថុធាតុដើម និងមិនទាន់មានអ្នកបញ្ជាទិញ ដែលជាមូលហេតុធ្វើអោយសង្វាក់ផលិតកម្មមិនអាចដំណើរការឱ្យបងប្អូនកម្មករនិយោជិតបានធ្វើការងារពេញលេញឡើយ។ ហេតុដូចច្នេះថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនបានសម្រេចចិត្តព្យួរកិច្ចសន្យាការងារកម្មកនិយោជិតសរុបចំនួន ៥០៩នាក់ ស្រី៤០២ ក្នុងចំណោមកម្មករសរុប ៥០៩នាក់ រយៈពេល ២ខែ គឺចាប់ពីថ្ងៃទី២ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣ និងចូលធ្វើការវិញនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ បងប្អូនកម្មករនិយោជិតបានយល់ព្រម និងឯកភាពទទួលយកប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម ៖

១.ភាគីក្រុមហ៊ុន ឯកភាពផ្តល់ប្រាក់ឧបត្ថម្ភចំនួន $ 30 (សាមសិបដុល្លារអាមេរិក) ក្នុងមួយខែ និងកំណត់បើកជូនបងប្អូនកម្មករនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

កិច្ចប្រជុំនេះ បានចប់នៅវេលាម៉ោងដប់ និងសែសិបប្រាំនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមកិច្ចព្រមព្រៀងគ្នាដោយស្មារតីយោគយល់គ្នា សហការគ្នា និងការទទួលខុសត្រូវខ្ពស់បំផុត ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កណ្តាល ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២
**ហត្ថលេខា និងត្រានាយកក្រុមហ៊ុន**

NEO MERIDIAN INDUSTRIES GARMENTS (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

CHEN WENJIE



CamScanner

## ស្នាមមេដៃ ប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក

| | | | |
|---|---|---|---|
| ថោម ធឿន | ឈា សុភា | ហៃ ប៊ុនហន | ប៊ិត សាម៉េត |
| ស៊ឹម ជានិត | ពេញ ពេជ្រ | ហុង វុទ្ធី | ម៉ន លីដា |
| ហឿន ចន្ទី | ម៉ាលី ម៉ាលាប | ឈឹម ង៉ាន | ងួន សុឃីម |
| លី សារឿន | ពេជ្រ ពណ្ណរាយ | យុន បូណា | វុទ្ធី រដ្ឋា |
| អ៊ុច ស៊ីការ | នី រីណា | អ៊ុន ចន្ទី | សំ រឿន |
| ណាត ដានី | វ៉ុន ចំរើន | ធី ចាន់ថុល | ផាន់ វុត្ថា |
| ហី សុហ៊ាង | ធី ចន្ធូ | សុខ ស៊ីវត្ថី | អ៊ុន សីហា |



Scanned with CamScanner
CamScanner
CamScanner